# ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប

## ចក្ខុវិស័យឆ្នាំ២០៣៥

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ : ០០៤ សសរ

ថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ខេត្តសៀមរាប

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប

**សម្រេច**

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងសៀមរាប ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងសៀមរាប ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាបមុនពេលកំណត់អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប និងអភិបាលនៃគណៈអភិបាលក្រុងសៀមរាប និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងសៀមរាប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ.០០៤ សសរ... ចុះថ្ងៃ.............ខែ.........ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី.០៥...... ខែ.កញ្ញា... ឆ្នាំ២០១៨

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ខេត្តសៀមរាប

# ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប

## ចក្ខុវិស័យឆ្នាំ២០៣៥

# មាតិកា


ទំព័រ

១-សេចក្តីផ្តើម ............ ៣

២-ចក្ខុវិស័យ ............ ៤

២.១-ក្របខណ្ឌសេដ្ឋកិច្ច-សង្គម ............ ៤

២.២-ចក្ខុវិស័យ ............ ៤

៣-គោលបំណង និងគោលដៅ ............ ៥

៣.១-គោលបំណង ............ ៥

៣.២-គោលដៅ ............ ៥

៤-យុទ្ធសាស្ត្រអភិវឌ្ឍ និងអភិរក្សក្រុងសៀមរាប ............ ៥

៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព ............ ៥

៤.១.១-ការកំណត់ប្រភេទដីកម្រិតការសាងសង់ ............ ៦

៤.១.២-ការកំណត់ប្រភេទដីអាចសាងសង់បាន ............ ៧

៤.១.៣-ការអភិវឌ្ឍក្រុងនិងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព ............ ៨

៤.២-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ក្រុងសៀមរាប ............ ១០

៤.២.១-តំបន់ទេសចរណ៍បេតិកភណ្ឌ ប្រវត្តិសាស្ត្រ ............ ១១

៤.២.២-តំបន់ទេសចរណ៍វប្បធម៌ និងសោភណភាពក្រុង ............ ១១

៤.២.៣-តំបន់ទេសចរណ៍ធម្មជាតិ និងបឹងទន្លេសាប ............ ១២

៤.២.៤-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍ ............ ១២

៤.២.៥-ការអភិវឌ្ឍធនធានមនុស្ស ............ ១២

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម ............ ១៣

៤.៣.១-អ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្មតាមផ្លូវជាតិតភ្ជាប់ប្រទេសថៃ ខេត្តសៀមរាប និងរាជធានីភ្នំពេញ ............ ១៣

៤.៣.២-ផ្លូវថ្នល់ ............ ១៣

៤.៣.៣-ផ្លូវទឹក ............ ១៣

៤.៣.៤-ផ្លូវអាកាស ............ ១៣

៤.៣.៥-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ............ ១៤

៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌ ............ ១៤

៤.៣.៧-ការផ្គត់ផ្គង់ទឹកស្អាត ............ ១៤

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក ............ ១៥

៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច ............ ១៥

៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ ............ ១៥

៤.៦.១-ការគ្រប់គ្រងសំណល់រឹង ............ ១៥

៤.៦.២- ការគ្រប់គ្រងសំណល់រាវ........................................................................ ១៦
៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ...................................... ១៦
៤.៦.៤- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ.................................................... ១៦
៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ........................................................ ១៧
៤.៨- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន ....................................... ១៧
៥- ផែនការសកម្មភាព.................................................................................. ១៨
៥.១- ការរៀបចំបទប្បញ្ញត្តិនត្យូបនីយកម្ម.................................................................. ១៨
៥.២- ការផ្សព្វផ្សាយ .................................................................................... ១៨
៥.៣- ការអនុវត្តគម្រោងតាមវិស័យ........................................................................ ១៨
៥.៣.១- ការអភិវឌ្ឍក្រុង............................................................................... ១៨
៥.៣.២- អភិវឌ្ឍវិស័យទេសចរណ៍........................................................................ ១៨
៥.៣.៣- ការដឹកជញ្ជូន.................................................................................. ១៩
៥.៣.៤- ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល.............................................. ១៩
៥.៣.៥- ការគ្រប់គ្រងបរិស្ថាន ........................................................................... ១៩
៥.៣.៦- ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត.............................................................. ១៩
៥.៣.៧- ការគ្រប់គ្រងសំណល់រឹង........................................................................ ២០
៥.៣.៨- ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ ............................................ ២០
៥.៣.៩- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ ................................................. ២០
៥.៤- ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ............................................................. ២០
៥.៤.១- ការអនុវត្តរយៈពេលខ្លី.......................................................................... ២០
៥.៤.២- ការអនុវត្តរយៈពេលមធ្យម....................................................................... ២១
៥.៤.៣- ការអនុវត្តរយៈពេលវែង......................................................................... ២១
៥.៥- គម្រោងអាទិភាព.................................................................................... ២១
៦- ធនធានហិរញ្ញវត្ថុ.................................................................................... ២១
៧- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ...................................................... ២២
៧.១- យន្តការ ............................................................................................ ២២
៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត................................................ ២២
៧.៣- ភារកិច្ច គោលការណ៍ និងនីតិវិធី.................................................................. ២២
៨- អនុសាសន៍......................................................................................... ២៣
៩- សេចក្តីសន្និដ្ឋាន................................................................................... ២៣
ឯកសារឧបសម្ព័ន្ធ.................................................................................... ២៩

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យប្រសើរនូវវិធាននិងឧបករណ៍ចាំបាច់នានា តាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ក្រុងសៀមរាបត្រូវបានកំណត់ជាតំបន់ស្នូលនៃប៉ូលអភិវឌ្ឍជាតិ ជាទឹកដីអច្ឆរិយសម្បូរដោយប្រាង្គប្រាសាទបុរាណ ជាពិសេសមានប្រាសាទអង្គរវត្តជាសម្បត្តិបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញ ជាគោលដៅទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ដែលមានសក្តានុពលសេដ្ឋកិច្ចសម្បូរបែប និងមានភ្ញៀវទេសចរជាតិនិងអន្តរជាតិរាប់លាននាក់ចូលមកទស្សនាក្នុងមួយឆ្នាំៗ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍក្រុងសៀមរាប ប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុងសៀមរាប ក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំនូវ **ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥** ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍដែនដីក្រុងសៀមរាបទាំងមូល ស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីនេះ ត្រូវបានកសាងឡើងដោយការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីនេះ មានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់

ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្សតំបន់បេតិកភណ្ឌអង្គរ ដែលជាសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនិងធម្មជាតិ ដែលអាចរងការបំផ្លាញដោយសារសកម្មភាពអភិវឌ្ឍរបស់មនុស្ស ឬដោយសារការប្រែប្រួលអាកាសធាតុ ដូចជា ការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅក្នុងទីក្រុង របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។

**២-ចក្ខុវិស័យ**

**២.១-ក្របខណ្ឌសេដ្ឋកិច្ច-សង្គម**

ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាម គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី “សៀវភៅ ស ដីធ្លី” និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ២០៣៥ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ត្រូវបានសិក្សាក្របខណ្ឌសេដ្ឋកិច្ច-សង្គម ដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ក្រុងសៀមរាបមានផ្ទៃដី **៤៤១,៤៧ គីឡូម៉ែត្រក្រឡា** ចំនួនប្រជាជននៅឆ្នាំ ២០០៨ មានចំនួន **២២៤ ១១៦ នាក់** ឆ្នាំ ២០១៨ មានចំនួន **២៨៧ ៧៥៣ នាក់** និងនៅឆ្នាំ ២០៣៥ នឹងកើនឡើងដល់ **៤៤០ ០៩៩ នាក់** ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុងសៀមរាបនៅឆ្នាំ ២០០៨ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមាន **២១ ១៥៣ នាក់** (២០,៩%) ក្នុងវិស័យឧស្សាហកម្មធនស្រាលដែលជាសិប្បកម្មមាន **១៦ ៥៩៩ នាក់** (១៦,៤%) និងក្នុងវិស័យសេវាកម្មមាន **៦៣ ៤៥៩ នាក់** (៦២,៧%) ហើយរំពឹងថានៅឆ្នាំ ២០៣៥ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមានការកើនឡើងដល់ **៣៤ ៣២៨ នាក់**(១៥%) ក្នុងវិស័យឧស្សាហកម្មធនស្រាលដែលជាសិប្បកម្មមានការកើនឡើងដល់ចំនួន **៧៦ ៨៤៤ នាក់** (៣៣,៦%) និងក្នុងវិស័យសេវាកម្មមានការកើនឡើងដល់ចំនួន **១១៧ ៦៣០ នាក់** (៥១,៤ %)។

**២.២-ចក្ខុវិស័យ**

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប គឺសំដៅរៀបចំនិងអភិវឌ្ឍ **“ក្រុងសៀមរាបជាប៉ូលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ និងទេសចរណ៍ពិភពលោក”** តាមរយៈការជំរុញ÷ ១) លើកកម្ពស់កិច្ចការពារនិងអភិរក្សបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ, ២) ជុំរុញកិច្ច សេវាកម្មនិងផលិតផលទេសចរណ៍សម្បូរបែបប្រកបដោយគុណភាពខ្ពស់ ដែលភ្ញៀវទេសចរអាចមានអារម្មណ៍ជិតស្និទ្ធទៅនឹងប្រវត្តិសាស្ត្រ វប្បធម៌ខ្មែរ និងធម្មជាតិ, ៣) អភិវឌ្ឍក្រុងបេតិកភណ្ឌកម្រិតអន្តរជាតិប្រកបដោយគុណភាពបរិស្ថានរស់នៅល្អ ដែលមានហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មទីក្រុងសម្បូរបែប និងមានកម្រិតផងស៊ីតេនៃការរស់នៅសមស្របទៅនឹងបរិយាកាសបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ។

## ៣-គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប មានគោលបំណងនិងគោលដៅ ដូចខាងក្រោម÷

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប មានគោលបំណងធានាការគ្រប់គ្រងនិងអភិបាលកិច្ចក្រុងសៀមរាបឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយគុណភាព តុល្យភាព សមធម៌ និងចីរភាព។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប មានគោលដៅ÷

- គ្រប់គ្រងការប្រើប្រាស់ដី និងនគរូបនីយកម្ម ស្របទៅនឹងតំបន់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រពិភពលោកប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ចទាក់ទាញ គាំទ្រដល់ការវិនិយោគសាធារណៈនិងវិស័យឯកជន ដើម្បីសមធម៌សង្គម និងផ្តល់ការងារ
- លើកកម្ពស់បេតិកភណ្ឌពិភពលោក ធនធានធម្មជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាព នៃការកែលម្អ ការអភិវឌ្ឍ និងការពារហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយ និងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍ និងអភិរក្សក្រុងសៀមរាប

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប បានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម÷

### ៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

ផ្អែកលើអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ក្រុងសៀមរាបត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីកម្រិតការសាងសង់ និងប្រភេទដីអាចសាងសង់បាន។

យោងតាមអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលក្រុងសៀមរាបនិងស្រុកប្រាសាទបាគង ដោយកាត់សង្កាត់អំពិលនៃក្រុងសៀមរាប ទៅឱ្យស្រុកប្រាសាទបាគងនៃខេត្តសៀមរាប ក្រុងសៀមរាបមានផ្ទៃដីសរុប ៤៤ ១៤៧ ហិកតា ត្រូវបានកំណត់ជាប្រភេទដីកម្រិតការសាងសង់មានចំនួន **៣៥ ៩៩៥ ហិកតា** ស្មើនឹង ៨១,៥៣% នៃផ្ទៃដីក្រុងទាំងមូល និងប្រភេទដីអាចសាងសង់បានមានចំនួន **៨ ១៥២ ហិកតា** ស្មើនឹង ១៨,៤៧%។

### ៤.១.១-ការកំណត់ប្រភេទដីកម្រិតការសាងសង់

**ក) តំបន់ការពាររមណីយដ្ឋានវប្បធម៌**

តំបន់នេះត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ០០១ ន.ស. ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ដោយមានអាជ្ញាធរ"អប្សរា" ជាអ្នកការគ្រប់គ្រង។ ចំណាត់ថ្នាក់រមណីយដ្ឋានត្រូវបានកំណត់ដូចខាងក្រោម÷

- តំបន់ ១ ÷ **រមណីយដ្ឋានមានប្រាសាទ** គឺតំបន់នានាដែលមានស្ថានីយបុរាណសំខាន់ៗជាងគេក្នុងប្រទេសយើងហើយត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។ ធម្មតាតំបន់ទាំងអស់នេះមានទំហំតូច តែចំពោះតំបន់អង្គរវិញទោះមានផ្ទៃដីដ៏ធំធេងក៏ត្រូវចាត់ចែងការពារចូលក្នុងកម្រិតខ្ពស់បំផុតដែរ ដោយតំបន់នេះមានប្រាសាទ និងសំណល់បុរាណវត្ថុច្រើន។
- តំបន់ ២ ÷ **ឧទ្យានបុរាណវត្ថុត្រូវការពារ** គឺតំបន់នានាសម្បូរដោយសំណល់បុរាណវត្ថុ សំខាន់ៗជាងគេក្នុងប្រទេសយើង ដែលត្រូវការពារទប់ទល់នឹងការប្រើប្រាស់ដី និងការអភិវឌ្ឍមិនសមស្រប។ ធម្មតាតំបន់ទាំងនេះស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ។ តំបន់ទាំងនេះច្រើនមានបុរាណវត្ថុបង្កប់ក្នុងទីនោះ។ តំបន់នេះមានសារសំខាន់ជាចម្បងដោយសារជាតំបន់ទ្រនាប់សម្រាប់ការពាររមណីយដ្ឋានមានប្រាសាទ។

**ខ) តំបន់ការពារធនធានធម្មជាតិ និងជីវចម្រុះបឹងទន្លេសាប**

យោងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន **៦៤៧ ៤០៦ ហិកតា** ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប និងសៀវភៅសស្តីពីការបោះបង្គោលការពារព្រៃលិចទឹកជុំវិញបឹងទន្លេសាប បានកំណត់ថា បឹងទន្លេសាបគឺជាបឹងធំជាងគេបង្អស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍សម្បូរធនធានធម្មជាតិជីវចម្រុះក្នុងទឹកជាច្រើនប្រភេទ និងមានតំបន់ទំនាបនៅជុំវិញមាត់បឹងដែលកំណត់ជាតំបន់លិចទឹកនៅរដូវវស្សា។ ដោយឡែក ក្រុងសៀមរាបមានតំបន់ការពារជីវចម្រុះដែលត្រូវកំណត់ដូចខាងក្រោម÷

- ផ្ទៃបឹងទន្លេសាបចាំបាច់ត្រូវការពារ និងថែរក្សាជីវចម្រុះធម្មជាតិ ប្រើប្រាស់ជាគោលដៅទេសចរណ៍ធម្មជាតិ កំពង់ផែ ផ្លូវដឹកជញ្ជូន ប្រភពទឹកស្អាត និងទឹកស្រោចស្រព
- ផ្ទៃដីតំបន់ ៣ ដែលជាតំបន់ការពារព្រៃលិចទឹកបឹងទន្លេសាប មានទំហំប្រមាណ **១០ ៨៩៨ ហិកតា** ត្រូវការពារនិងទប់ស្កាត់ការកាប់បំផ្លាញនិងទន្ទ្រានយកដី ការនេសាទខុសច្បាប់ ការបរបាញ់សត្វគ្រប់ប្រភេទដើម្បីរក្សាព្រៃលិចទឹក សម្រាប់ចីរភាពបរិស្ថាន។

**គ) តំបន់ការពារធម្មជាតិ÷ ស្ទឹង បឹង អូរ ប្រឡាយ ត្រពាំង**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប និង/ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្តជាធរមាន ក្នុងការការពារដីសាធារណៈរបស់រដ្ឋ មានជាអាទិ៍ ស្ទឹង បឹង អូរ ប្រឡាយ ត្រពាំង ដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅ និងជាតិទាំងមូល។

**ឃ) ប្រព័ន្ធស្រោចស្រពកសិកម្ម**

ប្រព័ន្ធធារាសាស្ត្រស្រោចស្រពដំណាំកសិកម្ម ដែលមានប្រភពទឹកមកពីបឹងបារាយណ៍ខាងលិច និងបឹងទន្លេសាបដ៏មានសក្តានុពល ត្រូវស្តារ ការពារ និងថែរក្សាកុំឱ្យមានការចាក់ដីលុបបំពេញ ដើម្បីប្រើប្រាស់សម្រាប់

គាំទ្រដល់វិស័យកសិកម្មក្រុងនិងខេត្តសៀមរាប ព្រោះផលិតផលកសិកម្មធម្មជាតិនេះជាធាតុសំខាន់ ក្នុងការផ្គត់ផ្គង់ជាអាហារ ត្រី សាច់ សម្រាប់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរដែលចូលមកទស្សនានៅខេត្តសៀមរាប។

**ខ) តំបន់ការពារបុរាណដ្ឋានចំនួន ១០៣៣**

តំបន់បុរាណដ្ឋានចំនួន ១០៣៣ ត្រូវការពារ រួមមាន បុរាណដ្ឋានជាប្រាសាទចំនួន ៣៩៤ បុរាណដ្ឋានជាស្ពានចំនួន ៧៩ និងបុរាណដ្ឋានជាទំនប់បុរាណ ទួលបុរាណ ស្រះ និងប្រឡាយបុរាណ និងបុរាណដ្ឋានផ្សេងៗទៀតចំនួន ៥៦០ ក្នុងខេត្តសៀមរាប។

**គ) តំបន់កសិកម្ម**

- រក្សាផ្ទៃដីកសិកម្មដោយអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប
- ធ្វើផែនការគ្រប់គ្រងផ្ទៃដីកសិកម្មដោយធ្វើការកំណត់ និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់ រួមមាន តំបន់កសិកម្មភាគខាងលិច និងខាងត្បូងក្រុង ដែលមានប្រព័ន្ធធារាសាស្ត្រស្រាប់ តំបន់កសិកម្មបឹងទន្លេសាប តំបន់កសិកម្មតាមប្រាសាទ និងតំបន់កសិកម្មភាគខាងកើតក្រុង
- សិក្សាផែនការពង្រីកក្រុងតាមបច្ចេកទេសទំនើប ដើម្បីកាត់បន្ថយជាអតិបរមាដល់ផ្ទៃដីកសិកម្មដែលបានបម្រុងទុក
- អភិវឌ្ឍកសិកម្មនិងបង្កើនផលិតភាពកសិកម្មតាមភូមិនៅក្នុងតំបន់ការពារប្រាសាទ។

**៤.១.២-ការកំណត់ប្រភេទដីអាចសាងសង់បាន**

ផ្អែកលើព្រះរាជក្រឹត្យលេខ ០០១ ន.ស. ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ផ្ទៃដីក្នុងតំបន់អាចសាងសង់បាន រួមមាន÷

- តំបន់ ៣ **ទេសភាពវប្បធម៌ត្រូវការពារ÷** គឺតំបន់នានាដែលមានលក្ខណៈ ជាទេសភាពដែលត្រូវការពារ ដោយហេតុថា តំបន់នេះមានទិដ្ឋភាពបរមបុរាណ។ លើសពីនេះទៅទៀត បែបបទប្រើប្រាស់ដីធ្លី សំណង់លំនៅឋាន អគារប្រវត្តិសាស្ត្រនៅទីនោះដែលជាកេរដំណែលដ៏យូរលង់ ផ្តល់តម្លៃវប្បធម៌ខ្ពស់ ឆ្លុះបញ្ចាំងពីជីវភាពរស់នៅពីអតីតកាល។ ទេសភាពវប្បធម៌នេះជាមធ្យោបាយរក្សាទស្សនៈវិស័យ ព្រមទាំងទំនាក់ទំនងរវាងទេសភាពលេចធ្លោនានា។ ទេសភាពវប្បធម៌ត្រូវការពារនេះ ត្រូវមានការគ្រប់គ្រងដោយច្បាប់ទម្លាប់ទប់ទល់នឹងសកម្មភាពបំផ្លិចបំផ្លាញ បង្ខិតបង្ខោច។
- តំបន់ ៤ **ចំណុចមានសារសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យា÷** គឺតំបន់ផ្សេងៗទៀតដែលមានសារប្រយោជន៍ខាងបុរាណវិទ្យា តែមានសារសំខាន់កម្រិតទាបជាងរមណីយដ្ឋានមានប្រាសាទ។ តំបន់នេះ ត្រូវរក្សាការពារជាប្រយោជន៍ដល់ការស្រាវជ្រាវ ការអប់រំ ឬទេសចរណ៍។ កិច្ចការពារនិងច្បាប់ទម្លាប់គ្រប់គ្រងត្រូវមានកម្រិតដូចគ្នានឹងឧទ្យានបុរាណវត្ថុដែរ។
- តំបន់ ៥ **បរិវេណអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌នៃតំបន់សៀមរាបអង្គរ÷** បរិវេណនេះគ្របដណ្តប់ខេត្តសៀមរាបទាំងមូល ក្នុងគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌និងធម្មជាតិ ត្រូវចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ដោយមានវិធានការការពារបរិស្ថាន។

ខាងលើនេះ ជានិយមន័យដែលបានចែងដោយព្រះរាជក្រឹត្យ ហើយតំបន់ទាំង ៣ នេះ គឺអាចធ្វើការសាងសង់បានប៉ុន្តែក្នុងករណីការសាងសង់មានប្រទះឃើញនូវខឿនប្រាសាទ ទួលប្រាសាទឬសំណល់បុរាណវត្ថុ ការសាងសង់ត្រូវបញ្ឈប់និងរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច។

**៤.១.៣ - ការអភិវឌ្ឍក្រុងនិងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព**

**ក) តំបន់ក្រុងបច្ចុប្បន្ន**

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- កែលម្អ និងស្តារស្ទឹងសៀមរាប សួនច្បារតាមមាត់ស្ទឹង ផ្លូវ និងភ្លើងបំភ្លឺ ឱ្យមានសោភណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់និងពេលថ្ងៃ សមស្របជាទីកន្លែងអច្ឆរិយបេតិកភណ្ឌ
- កែលម្អ និងស្តារ ផ្លូវជាតិលេខ ៦ និងផ្លូវក្រវាត់ក្រុង ចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺ ផ្លាកសញ្ញាចរាចរ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម ឱ្យមានសោភណភាព សណ្តាប់ធ្នាប់ គុណភាពបរិស្ថានល្អ សមស្របជាខ្លោងទ្វារនិងអ័ក្សមេនៃក្រុងទេសចរណ៍
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លំហសាធារណៈ កំណត់ប្រភេទនិងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងសៀមរាបស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយសុខភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- គ្រប់គ្រងការអភិវឌ្ឍនិងអភិរក្សសំណង់អគារបេតិកភណ្ឌក្នុងតំបន់កណ្តាលក្រុង ផ្សាររាត្រី ផ្សារចាស់ ដែលជាទីកន្លែងកម្សាន្តដ៏មានប្រជាប្រិយភាពរបស់ក្រុង ប្រកបដោយប្រសិទ្ធភាព ចីរភាព សុវត្ថិភាព សោភណភាព សណ្តាប់ធ្នាប់ និងបរិស្ថានរស់នៅល្អ
- កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ មានផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹងនិងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភណភាពក្រុង
- រៀបចំនិងកំណត់រចនាបថអគារ ពណ៌អគារ និងកំណត់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវនិងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់និងសោភណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រជាទីក្រុងបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ ប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ។

**ខ) ទិសដៅនគរូបនីយកម្ម**

- និន្នាការនៃការអភិវឌ្ឍទីក្រុងនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកទៅកាន់តំបន់ភាគខាងកើតនិងខាងត្បូងនៃទីក្រុងបច្ចុប្បន្ន ហើយក៏ត្រូវស្ថិតនៅខាងក្រៅតំបន់បេតិកភណ្ឌ និងតំបន់

ដីកសិកម្មដែលមានប្រព័ន្ធធារាសាស្ត្រភាគខាងលិច និងត្រូវធានាបានកម្រិតដង់ស៊ីតេសមស្របជាទីក្រុងបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ

- គ្រប់គ្រងការអភិវឌ្ឍនិងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍប្រវត្តជាពិសេសបណ្ដាញផ្លូវ ប្រព័ន្ធលូ អាងប្រព្រឹត្តិកម្ម និងចៀសវាងការសាងសង់មុនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ពង្រឹងសមត្ថភាពមន្ត្រីធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងការអភិវឌ្ឍ ជាពិសេស ប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តនិងក្រុង ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាល ជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តការងាររៀបចំដែនដី និងនគរូបនីយកម្ម។

**ឥ) តំបន់អភិវឌ្ឍក្រុង**

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីអាចសាងសង់បានត្រូវបានបែងចែកជាតំបន់។ សំណង់នៅក្នុងតំបន់នីមួយៗត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា **១,៥** ជួរតម្រង់ ឆ្លាតម្ហូត ពណ៌ កម្ពស់ សោភណភាព និងមានរចនាបទស្ថាបត្យកម្មខ្មែរ និង/ ឬ មានធម្មជាតិត្រឹមត្រូវ ស្របតាមការបែងចែកតំបន់នៃផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន និងបែងចែកជាតំបន់ប្រើប្រាស់ដីដូចខាងក្រោម÷

- តំបន់លំនៅឋាន÷ ស្ថិតនៅសង្កាត់ស្លក្រាម សាលាកំរើក ស្វាយដង្គុំ និងផ្នែកខ្លះនៃសង្កាត់ស្រង៉ែ សំបួរ សៀមរាប និងសង្កាត់ជ្រាវ ចន្លោះភាគខាងត្បូងនៃតំបន់ឧទ្យានបុរាណវត្ថុត្រូវការពារ និងតំបន់កសិកម្ម ដែលមានទំហំផ្ទៃដីសរុបប្រមាណ **៤ ៧៦៧ ហិកតា** ស្មើនឹង ៥៨,៤៨% នៃផ្ទៃដីអាចសាងសង់បាន។ តំបន់លំនៅឋានត្រូវបានបែងចែកជាតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប និងតំបន់លំនៅឋានចម្រុះ។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៥០% នៃផ្ទៃដីឡូត៍។
- តំបន់ពាណិជ្ជកម្ម÷ ស្ថិតនៅផ្សារលើ ផ្សារចាស់ ផ្សារក្រោម ផ្សាររាត្រី ជុំវិញផ្សារ និងតាមបណ្ដោយផ្លូវជាតិលេខ **៦** និងមហាវិថី ក្នុងសង្កាត់ស្លក្រាម សាលាកំរើក ស្វាយដង្គុំ និងសង្កាត់ជ្រាវ មានផ្ទៃដីសរុបទំហំប្រមាណ **៣០៥ ហិកតា** ស្មើនឹង ៣,៧៤% នៃផ្ទៃដីអាចសាងសង់បាន។ តំបន់ពាណិជ្ជកម្មចែកជាតំបន់ពាណិជ្ជកម្មជាផ្សារ និងតំបន់ពាណិជ្ជកម្មចម្រុះ។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍។
- តំបន់ចម្រុះ÷ ស្ថិតនៅសង្កាត់ស្លក្រាម សាលាកំរើក ស្វាយដង្គុំ និងផ្នែកខ្លះនៃសង្កាត់ស្រង៉ែ សៀមរាប និងសង្កាត់ជ្រាវ ភាគច្រើនស្ថិតនៅជុំវិញតំបន់ពាណិជ្ជកម្មនិងទេសចរណ៍ មានផ្ទៃដីសរុបទំហំប្រមាណ **១ ៧១៦ ហិកតា** ស្មើនឹង **២១,០៥%** នៃផ្ទៃដីអាចសាងសង់បាន។ តំបន់នេះប្រើប្រាស់បានច្រើនមុខងារ សម្រាប់ជាលំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្មដោយធានាបាននូវបរិស្ថានល្អ។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍។
- តំបន់សិប្បកម្ម÷ ក្រុងសៀមរាបមិនមានតំបន់ឧស្សាហកម្មទេ គឺមានតែតំបន់សិប្បកម្មផលិតផលទេសចរណ៍ ស្ថិតនៅក្នុងសង្កាត់ស្លក្រាម គោកចក និងសង្កាត់នគរធំ ដែលជាតំបន់

ការពារឧទ្យានអង្គរ និងគួរសិក្សាផ្លាស់ប្តូរទីតាំងចេញពីតំបន់ការពារឧទ្យានអង្គរ ឱ្យទៅទីតាំងជាយក្រុងក្រៅពីតំបន់អភិរក្ស។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៤០% នៃផ្ទៃដីឡូត៍។

- តំបន់ដីកជញ្ជូន÷ មានកំពង់ផែភ្នំក្រោម ចំណតរថយន្តក្នុងសង្កាត់ជ្រាវ និងចំណតរថយន្តក្រុងក្នុងសង្កាត់ស្រង៉ែ មានទំហំផ្ទៃដីសរុបប្រមាណ **៨៣ ហិកតា** ស្មើនឹង ១,០២% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៤០% នៃផ្ទៃដីឡូត៍។
- តំបន់ទេសចរណ៍÷ ស្ថិតនៅតាមដងស្ទឹងសៀមរាប បណ្តោយផ្លូវជាតិលេខ ៦ និងបុរីសណ្ឋាគារ និងតំបន់អភិវឌ្ឍទេសចរណ៍ មានទំហំផ្ទៃដីសរុបប្រមាណ **៨៦៤ ហិកតា** ស្មើនឹង ១០,៦០% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៥០% នៃផ្ទៃដីឡូត៍។
- តំបន់រដ្ឋបាលនិងសេវាសាធារណៈ÷ តំបន់រដ្ឋបាលប្រមូលផ្តុំនៅសាលាខេត្ត សាលាក្រុង សាលាសង្កាត់ និងតំបន់សេវាកម្មសាធារណៈក្នុងក្រុងសៀមរាប មានផ្ទៃដីសរុបទំហំប្រមាណ **៧៤ ហិកតា** ស្មើនឹង ០,៩១% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៤០% នៃផ្ទៃដីឡូត៍។
- តំបន់ល់ហសាធារណៈនិងផ្ទៃបៃតង÷ ស្ថិតតាមបណ្តោយស្ទឹងសៀមរាប ទីលានកីឡា តាមផ្លូវជាតិលេខ ៦ និងតំបន់ល់ហសាធារណៈក្នុងក្រុង មានផ្ទៃដីសរុបទំហំប្រមាណ **១៩៦ ហិកតា** ស្មើនឹង ២,៤០% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៩០% នៃផ្ទៃដីឡូត៍។
- តំបន់វប្បធម៌និងសាសនា÷ មានវត្តអារាម ព្រះវិហារសាសនា និងទីសក្ការបូជា មានទំហំផ្ទៃដីសរុបប្រមាណ **៤២ ហិកតា** ស្មើនឹង ០,៥២% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងយ៉ាងតិច ៥០% នៃផ្ទៃដីឡូត៍។
- តំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស÷ មានអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្ថានីយបូមបន្ត ស្ថានីយចម្រោះទឹកស្អាត ស្ថិតក្នុងសង្កាត់ស្វាយដង្គំ សៀមរាប និងជ្រាវ មានទំហំផ្ទៃដីសរុបប្រមាណ **១០៥ ហិកតា** ស្មើនឹង ១,២៩% នៃផ្ទៃដីអាចសាងសង់បាន។ រក្សាផ្ទៃបៃតងឱ្យបានយ៉ាងតិច ៥០% នៃផ្ទៃដីឡូត៍។

**៤.២- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ក្រុងសៀមរាប**

ការកំណត់ និងបែងចែកតំបន់តាមសក្តានុពលទេសចរណ៍ត្រូវបានបែងចែកដូចខាងក្រោម÷

- **តំបន់ទេសចរណ៍បេតិកភណ្ឌ ប្រវត្តិសាស្ត្រ** ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ ០០១ ន.ស. ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ គឺតំបន់ ១ និងតំបន់ ២ ដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា
- **តំបន់ទេសចរណ៍វប្បធម៌ និងសោភណភាពក្រុង** ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៦ តាមបណ្តោយដងស្ទឹងសៀមរាប និងផ្នែកកណ្តាលក្រុង
- **តំបន់ទេសចរណ៍ធម្មជាតិ និងបឹងទន្លេសាប** ស្ថិតនៅតំបន់កសិកម្មភាគខាងត្បូង តំបន់លិចទឹកបឹងទន្លេសាប និងបឹងទន្លេសាប
- **តំបន់រមណីយដ្ឋានទេសចរណ៍នៅឆ្ងាយពីតំបន់អង្គរ** មានតំបន់ទេសចរណ៍នានានៅតាមស្រុក ក្នុងខេត្តនិងនៅតាមបណ្តាខេត្តផ្សេងៗ។

**៤.២.១-តំបន់ទេសចរណ៍បេតិកភណ្ឌ ប្រវត្តិសាស្ត្រ**

- ជំរុញការរៀបចំអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងការរៀបចំទេសចរណ៍កែច្នៃ ជាពិសេសតាមផ្លូវទស្សនាប្រាសាទ និងបរិវេណប្រាសាទ
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារប្រាសាទ ទេសភាពវប្បធម៌ និងធម្មជាតិជុំវិញ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- ជំរុញការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ដោយសហការជាមួយផ្នែកឯកជនក្នុងការផលិតឯកសារផ្សព្វផ្សាយ និងសកម្មភាពផ្សព្វផ្សាយទាំងក្នុងនិងក្រៅប្រទេស
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ទាំងមូល ហើយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អនុតំបន់និងតំបន់
- ជំរុញកិច្ចសហការជាមួយក្រុមហ៊ុនភាពយន្ត និងក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ដើម្បីរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានានៅក្នុងខេត្ត
- ជំរុញការឃោសនាផ្សព្វផ្សាយ និងទាក់ទាញឱ្យមានការហោះហើរត្រង់ និងនាំភ្ញៀវទេសចរណ៍មកខេត្តសៀមរាបឱ្យបានច្រើន
- យកចិត្តទុកដាក់និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬ មធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេស ត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋានព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់។

**៤.២.២-តំបន់ទេសចរណ៍វប្បធម៌ និងសោភណភាពក្រុង**

- ជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ រួមមានជាអាទិ៍ រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន សេវាកម្សាន្តទេសចរណ៍ ទេសចរណ៍ផ្នែកធុរៈកិច្ចទេសចរណ៍ផ្នែកប្រជុំ សន្និសីទនិងពិព័រណ៍ (MICE) និងប្រភេទទេសចរណ៍ចាំបាច់នានា
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សាររាត្រី លំនៅឋានទេសចរណ៍
- កែលម្អនិងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវសម្រាប់ដឹកជញ្ជូន និងផ្លូវថ្មើរជើង សម្រាប់មនុស្សទាំងអស់គ្នា ដោយរៀបចំឱ្យមានផ្លូវសម្រាប់រថយន្ត កង់ ថ្មើរជើង និងបណ្តាញបៃតង ធានាបាននូវសោភណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- ធ្វើសមាហរណកម្មផែនការអភិវឌ្ឍទេសចរណ៍ទៅក្នុងផែនការអភិវឌ្ឍទីក្រុង ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព
- ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសាធារណៈ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពលួច ឆក់ ការបាត់បង់របស់របរ របស់ភ្ញៀវ នៅតាមកន្លែងកម្សាន្ត និងកន្លែងស្នាក់នៅជាដើម

- សុវត្ថិភាពចំណីអាហារក៏ត្រូវតែយកចិត្តទុកដាក់ ដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដារ និងបញ្ហាជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ។

**៤.២.៣-តំបន់ទេសចរណ៍ធម្មជាតិ និងបឹងទន្លេសាប**

- ជំរុញការរៀបចំអភិវឌ្ឍផលិតផលទេសចរណ៍ធម្មជាតិ និងទេសចរណ៍កែច្នៃលើបឹងទន្លេសាប ប្រកបដោយការប្រុងប្រយ័ត្ន និងការទទួលខុសត្រូវ
- រៀបចំចងក្រងសហគមន៍ និងបញ្ចូលសកម្មភាពទេសចរណ៍នៅក្នុងសហគមន៍ដែលមានសក្តានុពលទេសចរណ៍
- ជម្រុញការកែច្នៃ និងលក់ផលិតផលក្នុងតំបន់ជូនភ្ញៀវទេសចរ
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារធនធាន និងជីវចម្រុះបឹងទន្លេសាប
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតទូក ផ្លាកសញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- យកចិត្តទុកដាក់ និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬ មធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេស ត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់។

**៤.២.៤-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍**

រាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់ក្នុងការដាក់ចេញ និងបន្តអនុវត្តនូវគោលនយោបាយបើកចំហដើងមេឃ ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក និងយុទ្ធសាស្ត្រ "**អង្គរជាប៉ូលអាទិភាព**" ដើម្បីជួយគាំទ្រការអភិវឌ្ឍទេសចរណ៍កម្ពុជា។ ជាងនេះទៀត រាជរដ្ឋាភិបាលបន្តយ៉ាងសកម្ម ដោយសហការជាមួយដៃគូអភិវឌ្ឍនិងផ្នែកឯកជន និងការចូលរួមរបស់ប្រជាជន ក្នុងការអភិវឌ្ឍគោលដៅទេសចរណ៍ ផលិតផលទេសចរណ៍នៅជុំវិញ ឬតភ្ជាប់ជាមួយអង្គរដើម្បីគោលដៅចម្បង គឺការប្រើប្រាស់និរអស់លទ្ធភាព នូវធនធានដែលមានប្រកបដោយការទទួលខុសត្រូវ ដើម្បីអភិវឌ្ឍទេសចរណ៍ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គមនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ គ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍ទាំងវប្បធម៌និងធម្មជាតិ ត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយ ទាក់ទាញទេសចរទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រងនិងអភិវឌ្ឍនៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ ជូនប្រជាជនមូលដ្ឋានគឺជាអាទិភាព។ ដូចនេះ អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធត្រូវយកចិត្តទុកដាក់÷

- រៀបចំ និងបង្កើតខ្សែទស្សនកិច្ចទេសចរណ៍
- កែលម្អ និងបង្កើតផលិតផលទេសចរណ៍
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

**៤.២.៥-ការអភិវឌ្ឍធនធានមនុស្ស**

- ជំរុញការបណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍទេសចរណ៍នៅក្នុងខេត្តសៀមរាប
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍នៅក្នុងខេត្ត

- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈខេត្តសៀមរាបលើវិស័យទេសចរណ៍
- ចលនាផ្ទៃកងកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។

**៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម**

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹង និងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថាននៅក្នុងក្រុងសៀមរាប រួមមាន÷

**៤.៣.១- អ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្មតាមផ្លូវជាតិតភ្ជាប់ប្រទេសថៃ ខេត្តសៀមរាប និងរាជធានីភ្នំពេញ**

ផ្លូវជាតិលេខ ៦ ជាផ្លូវជាតិសំខាន់ជាងគេ ដែលមានតួនាទីជា**អ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្ម** ចាំបាច់ត្រូវពង្រីកទទឹងផ្លូវដែលមានស្រាប់ និងធ្វើការសាងសង់ផ្លូវវាងក្រុងនៅភាគខាងត្បូងបន្ថែមដែលមិនប៉ះពាល់ដល់តំបន់បេតិកភណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូន និងចរាចរណ៍។

**៤.៣.២- ផ្លូវថ្នល់**

- រៀបចំ និងកែលម្អផ្លូវពាណិជ្ជកម្ម និងផ្លូវទេសចរណ៍ ដោយកំណត់ផ្លូវជាតិលេខ ៦ ជាផ្លូវសម្រាប់ទេសចរណ៍ និងចរាចរណ៍ធុនស្រាល
- រៀបចំ និងកែលម្អផ្លូវក្រវាត់ក្រុងទី ១ ទី ២ សម្រាប់ការដឹកជញ្ជូនទូទៅ ជាពិសេសការធ្វើចរាចរណ៍ដែលមានទំនាក់ទំនងជាមួយក្រុងសៀមរាប
- កសាង និងកែលម្អផ្លូវក្រវាត់ក្រុងទី ៣ ឬផ្លូវវាងក្រុងភ្ជាប់ពីផ្លូវជាតិលេខ ៦ ក្រៅពីទីប្រជុំជនស្រុកពួក កាត់តាមក្រុងសៀមរាបភាគខាងត្បូង ភ្ជាប់ទៅផ្លូវជាតិលេខ ៦ ក្រៅពីទីប្រជុំជនស្រុកប្រាសាទបាគង ដែលជាផ្លូវបម្រើដល់វិស័យដឹកជញ្ជូន ពាណិជ្ជកម្ម និងទេសចរណ៍
- រៀបចំកសាង និងកែលម្អផ្លូវស្របតាមបណ្តោយដងស្ទឹងសៀមរាបឱ្យមានគុណភាព និងសោភណភាព ស្របតាមគោលការណ៍អភិវឌ្ឍបៃតង និងជាតំបន់ទេសចរណ៍វប្បធម៌ធម្មជាតិ
- រៀបចំ និងកែលម្អចំណតរថយន្តសាធារណៈ ស្របតាមបទដ្ឋានទីក្រុងបេតិកភណ្ឌពិភពលោក
- កសាង និងកែលម្អស្ថាន ចំណតរថយន្តសាធារណៈ ប្រព័ន្ធផ្លូវក្រវាត់ក្រុង ក្នុងក្រុង និងតំបន់បេតិកភណ្ឌ
- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

**៤.៣.៣- ផ្លូវទឹក**

- ស្តារ អភិវឌ្ឍ និងធ្វើទំនើបកម្មកំពង់ផែភ្នំក្រោម និងកំពង់ផែមួយចំនួនទៀតដែលគាំទ្រដល់តំបន់ទេសចរណ៍ និងការអភិវឌ្ឍរបស់ក្រុងនិងខេត្ត
- រៀបចំ និងកសាងកំពង់ផែទេសចរណ៍ និងមធ្យោបាយដឹកជញ្ជូនអ្នកដំណើរតាមស្ទឹងសៀមរាប
- រៀបចំប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការ។

**៤.៣.៤- ផ្លូវអាកាស**

- ស្តារ ពង្រីកបន្ថែម និងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ស្របតាមតម្រូវការកំណើនសេដ្ឋកិច្ច និងភ្ញៀវទេសចរ។

### ៤.៣.៥-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ជំរុញ ស្តារ និងអភិវឌ្ឍវិស័យ ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

### ៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- ជំរុញ ស្តារ និងរៀបចំលំហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈនិងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់កម្រិត តាមភូមិ សង្កាត់ ក្នុងក្រុងសៀមរាប ស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ និសថស្ថាន នៅតាមសង្កាត់ និងក្នុងក្រុងស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល។

### ៤.៣.៧-ការផ្គត់ផ្គង់ទឹកស្អាត

#### ក) ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្រុង

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងក្រុងសៀមរាប។ ប្រព័ន្ធដែលមានស្រាប់ ត្រូវកែលម្អ និងពង្រីកបន្ថែម ដើម្បីរក្សាគុណភាពជាមួយកំណើនប្រជាជន។ តម្រូវការបន្ទាន់បំផុតសម្រាប់ការកែលម្អនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ក្រុងសៀមរាប គឺមានដូចខាងក្រោម÷

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែលអាចមាន
- សិក្សាប្រភពទឹកផ្សេងៗ ដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់ក្រុង ដោយចៀសវាងការប្រើប្រាស់ប្រភពទឹកក្រោមដី
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង
- ស្តារឡើងវិញ និងការដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើនគុណភាពទឹក
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងដើម្បីបង្កើនប្រាក់ចំណូល
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស។

៣) ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជាយក្រុង

- ការពារប្រភពទឹកធម្មជាតិ
- ស្តារ និងកែលម្អអាងស្តុកទឹក និងបណ្តាញចែកចាយទឹកដែលមានស្រាប់ ដើម្បីអភិវឌ្ឍ និងផ្គត់ផ្គង់ទឹកស្អាត
- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក

ដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋានទទួលបានផលប្រយោជន៍ពីវិស័យទេសចរណ៍កាន់តែច្រើន គឺចាំបាច់ត្រូវ÷

- ការពារដីកសិកម្ម
- បង្កើនគុណភាពផលិតផល និងផ្សព្វផ្សាយអំពីផលិតផលផ្សេងៗ ដែលផលិតដោយកសិករនៅមូលដ្ឋាន ឬអ្នកជំនួញក្នុងស្រុកក្រោមម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ“**អង្គរ**” ក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងលក់ផលិតផលទាំងនេះទៅឱ្យភ្ញៀវទេសចរ និងកែលម្អ ពង្រីកទីផ្សារាត្រីបន្ថែម
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈភូមិមួយផលិតផលមួយ និងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរ និងរៀបចំផ្លូវកម្សាន្ត
- ការអភិវឌ្ឍផលិតផលកសិកម្មតាមតម្រូវការទីផ្សារទេសចរណ៍
- ពិនិត្យលទ្ធភាពក្នុងការកំណត់ទីតាំង រៀបចំ និងអភិវឌ្ឍតំបន់កសិកម្មតាមភូមិផ្សារភ្ជាប់ជាមួយទេសចរណ៍
- សិក្សាទីផ្សារ និងផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានអំពីស្តង់ដារបច្ចេកទេសកសិកម្មដល់ប្រជាជន
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវការធ្វើកសិកម្មដែលបំផ្លាញធនធានធម្មជាតិ ប្រើប្រាស់ជីនិងថ្នាំគីមី មិនគោរពតាមស្តង់ដារបច្ចេកទេស
- អភិវឌ្ឍធនធានមនុស្សតី ជំរុញការបណ្តុះបណ្តាលជំនាញដល់កសិករ ដោយអនុវត្តតាមស្តង់ដារកសិកម្ម និងចលនាផ្នែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន។

## ៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីសាធារណៈនិងឯកជនរបស់រដ្ឋ ជាពិសេសនៅតាមស្ទឹងសៀមរាប និងក្នុងតំបន់ការពារប្រាសាទ
- សិក្សាលទ្ធភាព និងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុង និងប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្នគ្រប់កន្លែង ជាពិសេសក្នុងតំបន់ការពារប្រាសាទ។

## ៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ

### ៤.៦.១- ការគ្រប់គ្រងសំណល់រឹង

- បង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងនិងខេត្តសៀមរាប
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង

- ជំរុញឱ្យមានការអនុវត្តគោលការណ៍ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃលើការគ្រប់គ្រងសំណល់រឹង
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងការវិនិយោគរបស់វិស័យឯកជន និងសាធារណៈ។

**៤.៦.២-ការគ្រប់គ្រងសំណល់រាវ**

- រៀបចំ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលបំពង់លូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្ម និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាពតំបន់បេតិកភណ្ឌពិភពលោក។

**៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន**

កំណត់ និងបែងចែកតំបន់ប្រើប្រាស់ដី ស្របតាមព្រះរាជក្រឹត្យលេខ ០០១ ន.ស. ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ និងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាបដូចខាងក្រោម៖

- តំបន់រមណីយដ្ឋានមានប្រាសាទ
- តំបន់ឧទ្យានបុរាណវត្ថុត្រូវការពារ
- តំបន់ទេសភាពវប្បធម៌ត្រូវការពារ
- តំបន់ចំណុចមានសារសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា
- តំបន់បរិវេណអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌នៃតំបន់សៀមរាបអង្គរ
- តំបន់ព្រៃលិចទឹកបឹងទន្លេសាបត្រូវការពារ
- តាមដងស្ទឹងសៀមរាប និងស្ទឹងរលួស
- តំបន់សហគមន៍។

**៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ**

- ការពារ និងថែរក្សា តំបន់រមណីយដ្ឋានមានប្រាសាទ តំបន់ឧទ្យានបុរាណវត្ថុត្រូវការពារ តំបន់ការពារទេសភាពវប្បធម៌ ព្រៃឈើ បឹង អូរ និង ប្រព័ន្ធបណ្តាញផ្លូវទឹក ស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារ និងថែរក្សាតំបន់ព្រៃលិចទឹកបឹងទន្លេសាប ដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃលិចទឹកឱ្យមានផលិតភាពខ្ពស់ និងមានសារៈសំខាន់នៅក្នុងអាយុកាលនៃជីវចម្រុះក្នុងបឹងទន្លេសាប ដូចជាមានតួនាទីសំខាន់ជាកន្លែងពង-កូន ឬកន្លែងរកចំណីសម្រាប់ធនធានជលផល និងសត្វព្រៃ
- ការពារ និងថែរក្សាព្រៃតំបន់ស្ទឹងសៀមរាប និងព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព

- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន តាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើនបំផុតក្នុងតំបន់ក្រុងនិងតំបន់បេតិកភណ្ឌ
- លើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងរមណីយដ្ឋានបេតិកភណ្ឌ
- កាត់បន្ថយការបូមយកទឹកក្រោមដីរបស់ឯកជន តាមរយៈការពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីរបស់ក្រុង
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថានដ៏មានប្រសិទ្ធភាពមួយនៅថ្នាក់ខេត្ត និងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាន និងជំរុញការវិនិយោគវិស័យឯកជននិងសាធារណៈ។

**៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ**

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារប្រាសាទ ទេសភាពវប្បធម៌ និងធម្មជាតិជុំវិញដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ទឹកក្រោមដី និងការប្រើប្រាស់ដី
- រៀបចំ ស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដោយអង្គភាពរដ្ឋាករស្វយ័តក្រុងសៀមរាបដល់ប្រជាជនក្នុងក្រុងឱ្យបាន ១០០% ដើម្បីបញ្ឈប់ការបូមទឹកក្រោមដីពីវិស័យឯកជន ដែលអាចនាំឱ្យបរិមាណទឹកក្រោមដីថយចុះនាំឱ្យបាក់ស្រុតប្រាសាទ
- សិក្សាប្រភពទឹកស្អាតពីបឹងទន្លេសាប ដើម្បីធានានូវតុល្យភាពនៃកម្ពស់ទឹកបារាយណ៍ខាងលិចសម្រាប់ទ្រទ្រង់ដល់ប្រាសាទនិងវិស័យទេសចរណ៍
- សិក្សា និងរៀបចំផ្លាស់ប្តូរទីតាំងអាកាសយានដ្ឋានអន្តរជាតិសៀមរាបបច្ចុប្បន្ន ទៅទីតាំងថ្មីសមស្រប និងធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ពីទីតាំងអាកាសយានដ្ឋានថ្មី មកក្រុងសៀមរាប និងតំបន់ជុំវិញ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ និងចំណតរថយន្ត ឱ្យស្ថិតនៅឆ្ងាយពីតំបន់ប្រាសាទ ដើម្បីការពាររំញ័ររបស់យានយន្តគ្រប់ប្រភេទដែលអាចប៉ះពាល់ដល់ប្រាសាទ
- ការពារធនធានធម្មជាតិ ជីវចម្រុះ ទាំងក្នុងតំបន់ឧទ្យានអង្គរ បឹងទន្លេសាប និងតំបន់ជុំវិញ ដើម្បីរក្សាបានតុល្យភាពបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។

**៤.៨- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន**

ការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ចអភិវឌ្ឍក្រុង និងបរិស្ថាន។ ដូច្នេះ ចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងខេត្ត
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ជាពិសេស សម្រាប់ការគ្រប់គ្រងអភិវឌ្ឍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ ។ល។
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន

- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេស សម្រាប់ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភណភាពនិងបរិស្ថានទីក្រុង។

**៥-ផែនការសកម្មភាព**

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប រដ្ឋបាលខេត្តសៀមរាប និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ ដូចតទៅ÷

**៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម**

តាមគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តសៀមរាប បទប្បញ្ញត្តិនគរូបនីយកម្ម ដែលត្រូវរៀបចំរួមមាន÷

- ផែនទីកំណត់កម្ពស់អគារក្នុងក្រុង និងសេវកិច្ចនៃកម្ពស់ហោះហើររបស់យន្តហោះ
- ផែនទីសំណង់អគារបេតិកភណ្ឌក្រុងសៀមរាប
- ផែនទីកំណត់ទីតាំងលំហសាធារណៈ ដូចជា ស្ទឹង បឹង ប្រឡាយ ផ្លូវថ្នល់ អាកាសយានដ្ឋាន កំពង់ផែ លំហបៃតង។ល។
- ផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព
- ប្លង់អភិវឌ្ឍទិសខាងត្បូង និងខាងកើត
- ប្លង់អភិវឌ្ឍទិសខាងលិច។

**៥.២- ការផ្សព្វផ្សាយ**

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាបនេះ ដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ និងតាមរយៈគេហទំព័រ ឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្តសៀមរាប។

**៥.៣- ការអនុវត្តគម្រោងតាមវិស័យ**

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុង ទេសចរណ៍ ការដឹកជញ្ជូន កសិកម្មនិងការផ្សព្វផ្សាយផលិតផល ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងគ្រប់គ្រងសំណល់រាវ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍ មានដូចខាងក្រោម÷

**៥.៣.១- ការអភិវឌ្ឍក្រុង**

- កែលម្អសោភណភាព និងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- កសាងសមត្ថភាពធ្វើផែនការក្រុង
- បញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មប្រវត្តិសាស្ត្រដែលមានតម្លៃសម្រាប់ការអភិរក្សក្នុងក្រុងសៀមរាប
- អភិវឌ្ឍតំបន់លំនៅឋាន
- ធ្វើផែនការ និងអភិវឌ្ឍតំបន់វប្បធម៌ តំបន់ទេសចរណ៍ តំបន់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងតំបន់សេវាកម្មកម្សាន្តទេសចរណ៍ផ្សេងៗ។

**៥.៣.២- អភិវឌ្ឍវិស័យទេសចរណ៍**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍បេតិកភណ្ឌអង្គរ

- អភិវឌ្ឍទីផ្សាររាត្រី
- លើកកម្ពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋ-ឯកជន
- លើកកម្ពស់ការអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិ
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមគោលការណ៍ដែលមានសក្តានុពល ដូចជា តាមភូមិសង្កាត់ ជាដើម
- បណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងការផ្តល់លិខិតអនុញ្ញាត
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន។

**៥.៣.៣-ការដឹកជញ្ជូន**

- កែលម្អស្ពានចាស់ៗពីសម័យមុននិងសាងសង់ស្ពានបន្ថែមសម្រាប់ឆ្លងកាត់ស្ទឹងសៀមរាប
- សាងសង់ផ្លូវវាណបស្របនឹងផ្លូវជាតិលេខ ៦
- សាងសង់និងកែលម្អផ្លូវក្រវាត់ក្រុង
- សាងសង់ផ្លូវវាងក្រុងផ្នែកខាងត្បូង
- កែលម្អបណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០២០
- សាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០២៥
- សាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០៣៥
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- ស្តារនិងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌនៅជនបទ
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថានក្នុងរមណីយដ្ឋានអង្គរ
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

**៥.៣.៤-ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល**

- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ
- ចលនាភូមិមួយ ផលិតផលមួយ
- អភិវឌ្ឍភូមិផលិតកម្ម
- តាំងពិព័រណ៍ផលិតផលអង្គរ។

**៥.៣.៥-ការគ្រប់គ្រងបរិស្ថាន**

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលកម្រៃពីសេវាកម្មសាធារណៈ។

**៥.៣.៦-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត**

- ត្រួតពិនិត្យអ្នកប្រើប្រាស់បណ្តាញផ្គត់ផ្គង់ទឹកស្អាត
- រៀបចំអនុក្រឹត្យស្តីពីតម្លៃប្រើប្រាស់ទឹកក្រោមដី
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកស្ទឹងសៀមរាប
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីក្នុងក្រុងសៀមរាប រហូតដល់ឆ្នាំ ២០៣៥

- អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន
- អភិវឌ្ឍស្ថានីយចម្រោះទឹកស្អាត និងប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងសៀមរាប រហូតដល់ឆ្នាំ ២០៣៥។

**៥.៣.៧-ការគ្រប់គ្រងសំណល់រឹង**

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់
- អភិវឌ្ឍកន្លែងចាក់សំរាមអនាម័យ។

**៥.៣.៨-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ**

- លើកកម្ពស់ប្រព័ន្ធបង្ហូរទឹកក្នុងក្រុង
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនិងសំណល់រាវក្នុងតំបន់កណ្តាលក្រុង
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនិងសំណល់រាវក្នុងតំបន់កណ្តាលក្រុងភាគខាងលិច
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនិងសំណល់រាវក្នុងតំបន់កណ្តាលក្រុងភាគខាងកើត
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកក្នុងក្រុងថ្មីនៅភាគខាងលិច
- គ្រប់គ្រងសំណល់រាវក្នុងក្រុង និងប្រព្រឹត្តិកម្មទឹកកខ្វក់
- គ្រប់គ្រងសំណល់រាវក្នុងតំបន់កណ្តាលក្រុងភាគខាងកើត និងប្រព្រឹត្តិកម្មទឹកកខ្វក់
- បញ្ចេញចោលសំណល់រាវបន្ទាប់ពីប្រព្រឹត្តិកម្មក្នុងតំបន់កណ្តាលក្រុងភាគខាងលិច
- បញ្ចេញចោលសំណល់រាវបន្ទាប់ពីប្រព្រឹត្តិកម្មក្នុងតំបន់កណ្តាលក្រុងភាគខាងកើត។

**៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍**

- បំពាក់ម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូត
- ពង្រីកស្ថានីយ៍ថាមពលប្រើប្រេងម៉ាស៊ូត
- ពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនី និងទូរគមនាគមន៍
- តំឡើង និងផ្គួសជុលបណ្តាញអគ្គិសនីបំភ្លឺតាមដងវិថី
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ប្រាសាទអង្គរ និងប្រាសាទផ្សេងៗទៀត
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ដែលពុំទាន់មានការប្រើប្រាស់
- កសាងសមត្ថភាពអគ្គិសនីកម្ពុជា
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ញា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន
- ស្រាវជ្រាវរកប្រភពថាមពលអគ្គិសនីប្រកបដោយចីរភាពសម្រាប់ក្រុងសៀមរាប។

**៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង**

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម៖

**៥.៤.១-ការអនុវត្តរយៈពេលខ្លី**

- គម្រោងអាទិភាពដូចបានបញ្ជាក់ខាងក្រោម
- ផែនការប្រើប្រាស់ដីក្រុងសៀមរាប ដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី និងសំណង់។

### ៥.៤.២-ការអនុវត្តរយៈពេលមធ្យម

គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

### ៥.៤.៣-ការអនុវត្តរយៈពេលវែង

- ចំពោះសំណង់បណ្តោះអាសន្នតាមដងស្ទឹងសៀមរាប និងការតាំងទីលំនៅ ត្រូវបន្តដោះស្រាយតាមសារាចរលេខ ០៣ សរ ស្តីពី ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន
- សិក្សាពីលទ្ធភាពនៃការធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាជនក្រីក្រគ្មានលំនៅឋាន និងប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្ន
- ចំពោះគម្រោងពង្រីកក្រុង ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជាបណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងទឹកភ្លៀង ប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង មានជាអាទិ៍ តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លំហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍអនាគត ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍបៃតង សំដៅធ្វើឱ្យទីក្រុងក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

## ៥.៥-គម្រោងអាទិភាព

- កែលម្អសោភណភាពនិងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- កសាងសមត្ថភាពធ្វើផែនការក្រុង
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍បេតិកភណ្ឌអង្គរ
- លើកកម្ពស់គុណភាពទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ-ឯកជន
- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ
- សាងសង់ផ្លូវវាងស្របនឹងផ្លូវជាតិលេខ ៦
- ស្តារនិងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌនៅជនបទ
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកស្ទឹងសៀមរាប
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនិងសំណល់រាវក្នុងតំបន់កណ្តាលក្រុង។

# ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប មានជាអាទិ៍÷

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍនិងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ

– ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្ត មាន៖ រដ្ឋបាលខេត្តសៀមរាប គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងសៀមរាប មន្ទីរ អង្គភាពរបស់ខេត្ត និងអាជ្ញាធរក្រុង សង្កាត់។

### ៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត មានជាអាទិ៍៖ ព្រះរាជក្រឹត្យស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្តីពីដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីការរៀបចំប្លង់គោល និង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣-ភារកិច្ច គោលការណ៍ និងនីតិវិធី

រដ្ឋបាលក្រុងសៀមរាប ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងសៀមរាបជាសេនាធិការ មានភារកិច្ច៖

– ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ៥ ឆ្នាំ កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង សង្កាត់។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដី និងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព

– ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល ៥ ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលានិងតម្រូវការចាំបាច់ជាក់ស្តែង សំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ

– ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប រដ្ឋបាលខេត្តសៀមរាប ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

**៨-អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប អនុវត្តមានប្រសិទ្ធភាព រដ្ឋបាលក្រុង-ខេត្តសៀមរាប និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់÷

ទី១).កំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាក្រុង និងបរិស្ថាននៃក្រុងសៀមរាប ក្នុងន័យទប់ស្កាត់លំហូរភ្ញៀវទេសចរចេញពីខេត្តសៀមរាប នៅពេលមានការប្រកួតប្រជែងខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀតនៅក្នុងប្រទេសជិតខាង និងពិភពលោក។

ទី២).ការគ្រប់គ្រងធនធានទឹកសម្រាប់ភ្ញៀវទេសចរ ប្រជាជនមូលដ្ឋាន និងការស្រោចស្រពដីកសិកម្មជាខ្សែក្រវាត់បៃតងរបស់ក្រុង។ ជាពិសេស នៅក្នុងតំបន់កណ្តាលក្រុងមិនត្រូវពឹងផ្អែកខ្លាំងលើការបូមយកទឹកក្រោមដីដែលអាចបណ្តាលឱ្យកម្រិតទឹកក្រោមដីធ្លាក់ចុះ និងការបាក់ស្រុតដីបង្កផលប៉ះពាល់ដល់ប្រាសាទក្នុងរមណីយដ្ឋានអង្គរ។

ទី៣).សម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួមពីប្រជាជនមូលដ្ឋាន ដើម្បីឱ្យការប្រើប្រាស់ដីអនុវត្តមានប្រសិទ្ធភាព។

ទី៤).ពិនិត្យវាយតម្លៃនិងកែលម្អប្លង់គោលប្រើប្រាស់ដីនេះរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង ដើម្បីឱ្យឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួលនិងតម្រូវការសេដ្ឋកិច្ចសង្គមជាក់ស្តែងក្នុងក្រុងនិងខេត្ត។

ទី៥).កសាងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់ក្រុងនិងខេត្ត និងលើកកម្ពស់ការចែករំលែកព័ត៌មាន អំពីគម្រោងអភិវឌ្ឍនានារវាងមន្ទីរជំនាញ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្ត។

ទី៦).លើកកម្ពស់សមត្ថភាពបច្ចេកទេសសម្រាប់ការត្រួតពិនិត្យ និងថែរក្សាបរិស្ថានក្រុងឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងខេត្ត។ ខេត្តត្រូវរៀបចំកញ្ចប់ថវិកាដល់អាជ្ញាធរក្រុងសម្រាប់ អនុវត្តផែនការជួសជុល និងថែទាំបរិក្ខារសាធារណៈ ដូចជា ផ្លូវក្នុងក្រុង សួនច្បារ ការប្រមូលសំណល់ និងប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ ។ល។ សម្រាប់អភិវឌ្ឍក្រុងសៀមរាបប្រកបដោយចីរភាព។

ទី៧).គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវជួយគាំទ្រដល់ខេត្តសៀមរាបក្នុងការកែលម្អបរិស្ថាន និងលើកកម្ពស់សោភណភាពទីក្រុងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

**៩-សេចក្តីសន្និដ្ឋាន**

ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប បានឆ្លុះបញ្ចាំងនូវកត្តាចំនួន ៣ សំខាន់ៗ គឺ ទី១).ការលើកកម្ពស់វិស័យទេសចរណ៍និងការអភិវឌ្ឍវិស័យកសិកម្មជនបទ តាមរយៈភូមិមួយ ផលិតផលមួយ និងការអភិវឌ្ឍភូមិផលិតកម្ម ជាចលករជំរុញសេដ្ឋកិច្ចក្រុងសៀមរាប ទី២).ការអភិរក្ស និងការអភិវឌ្ឍក្រុងឱ្យមានសោភណភាពទាក់ទាញដល់ភ្ញៀវ

ទេសចរ និងក្រុងមានបរិស្ថានល្អ ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍក្រុងសៀមរាបប្រកបដោយចីរភាព និងទី៣). ការកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងស្ថាប័នជាកត្តាគាំទ្រដល់ការអនុវត្តប្លង់គោលប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាព។ម្យ៉ាងវិញទៀត ប្លង់គោលប្រើប្រាស់ដីនេះ ជាមូលដ្ឋានសម្រាប់អនុវត្តការងារ បន្តធ្វើផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម ឬគម្រោងអភិវឌ្ឍក្រុង ដើម្បីគ្រប់គ្រងការអភិវឌ្ឍដីធ្លី និងសំណង់ក្នុងក្រុងសៀមរាបប្រកបដោយចីរភាព។

**ឯកសារឧបសម្ព័ន្ធ**

-រូបភាពទី ១÷ ការព្យាករណ៍អំពីចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០៣៥

-រូបភាពទី ២÷ ការព្យាករណ៍អំពីចំនួនប្រជាជនក្រុងសៀមរាប ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០៣៥

-រូបភាពទី ៣÷ ផែនទីរដ្ឋបាលក្រុងសៀមរាប

-រូបភាពទី ៤÷ ផែនទីតំបន់ការពារ និងគ្រប់គ្រងបរិស្ថាន

-រូបភាពទី ៥÷ ផែនទីបែងចែកតំបន់ប្រើប្រាស់ដី និងអភិវឌ្ឍន៍ក្រុងសៀមរាប

-រូបភាពទី ៦÷ ផែនទីស្ថានភាពរបាយប្រជាជនក្នុងក្រុងសៀមរាប

-រូបភាពទី ៧÷ ផែនទីបណ្ដាញផ្លូវក្រុងសៀមរាបឆ្នាំ ២០៣៥

-រូបភាពទី ៨÷ ផែនទីប្រើប្រាស់ដីបច្ចុប្បន្នរបស់ក្រុងសៀមរាប

-រូបភាពទី ៩÷ ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣៥។




រូបភាពទី ១÷ ការព្យាករណ៍អំពីចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០៣៥។ តាមការបញ្ជាក់របស់មន្ទីរទេសចរណ៍ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិសរុប ៦,០០០,០០០ នាក់ (ឆ្នាំ២០២៥) ៦,៥០០,០០០ នាក់ (ឆ្នាំ២០៣០) និង ៧,១០០,០០០ នាក់ (ឆ្នាំ២០៣៥)




រូបភាពទី ២÷ ការព្យាករណ៍អំពីចំនួនប្រជាជនក្រុងសៀមរាប ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០៣៥




រូបភាពទី៣÷ ផែនទីរដ្ឋបាលក្រុងសៀមរាប




រូបភាពទី ៤÷ ផែនទីតំបន់ការពារ និងគ្រប់គ្រងបរិស្ថាន




រូបភាពទី ៥÷ ផែនទីបែងចែកតំបន់ប្រើប្រាស់ដី និងអភិវឌ្ឍន៍ក្រុងសៀមរាប







រូបភាពទី ៦÷ ផែនទីស្ថានភាពរបាយប្រជាជនក្នុងក្រុងសៀមរាប




រូបភាពទី ៧÷ ផែនទីបណ្តាញផ្លូវក្រុងសៀមរាបឆ្នាំ ២០៣៥

## ផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នក្រុងសៀមរាបឆ្នាំ ២០១៥




រូបភាពទី ៨÷ ផែនទីប្រើប្រាស់ដីបច្ចុប្បន្នរបស់ក្រុងសៀមរាប




រូបភាពទី ៩÷ ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣៥

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តសៀមរាប
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងសៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ.......... ចុះថ្ងៃ.......... ខែ.......... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី.......... ខែ.......... ឆ្នាំ២០១៨













មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១:២៥០០០

0 0.5 1 2 3 4 គ.ម

សន្លឹកផែនទី: ១

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងនិងខេត្តសៀមរាប

ការគាំទ្របច្ចេកទេស: ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តសៀមរាប